# លក្ខន្តិកៈ ឌីខាក់

## មាត្រា I
## លំនាំដើម

សេចក្តីត្រូវការសំរាប់ជំនួយគាំទ្រលើកម្មវិធីសិក្សាសាធារណៈ គឺមានសារសំខាន់ណាស់ក្នុងពេលឥឡូវជាងពេលមុនៗមក ។ ចំពោះមាតាបិតា ដែលបានទទួលដឹងឮ និង ចូលរួមចំណែកនៅក្នុងការចាត់ចែងកម្មវិធីសិក្សាសំរាប់សិស្សរបស់ពួកគាត់ គឺច្រើនតែបង្ហាញសេចក្តីគាំទ្រមកលើកម្មវិធីនៅតាមសាលារៀន ។ ក្រុមប្រឹក្សាផ្តល់ឱវាទមាតាបិតា បើកឱកាសសំរាប់មាតាបិតាទទួលដឹងឮអំពីពត៌មាន និង ចូលរួមចំណែកជាមួយកម្មវិធីសិក្សានៃសិស្ស ។ ក្នុងការប្រព្រឹត្តស្របតាមច្បាប់ Title I Section 1118, សាលារៀនទាំងអស់នៅក្នុងក្រសួងអប់រំ ឌីស្ទ្រីគ ឡុងប៊ីច ឲ្យតែទទួលជំនួយថវិការមកពីរដ្ឋាភិបាលសហព័ន្ធ ឬ រដ្ឋ គឺនឹងមានឈ្មោះរួមចំណែកនៅក្នុង ក្រុមប្រឹក្សាផ្តល់ឱវាទរវាង ឌីស្ទ្រីគ/សហគមន៍ ។

## មាត្រា II
## ឈ្មោះនៃក្រុមប្រឹក្សា

ឈ្មោះនៃក្រុមប្រឹក្សានេះនឹងហៅថា ក្រុមប្រឹក្សាផ្តល់ឱវាទរវាង ឌីស្ទ្រីគ/សហគមន៍ ប្រចាំក្រសួងអប់រំ ឌីស្ទ្រីគ ឡុងប៊ីច ដែលប្រើជាអក្សរកាត់ហៅថា ឌីខាក់ – District Community Advisory Committee (DCAC) ។

## មាត្រា III
## គោលដៅ

គោលដៅនៃក្រុមប្រឹក្សា ឌីខាក់ គឺជួយក្រសួងអប់រំ ឌីស្ទ្រីគ តាមរយៈ ...

1. ផ្តល់ឱវាទ និង ជំនួយទូទៅក្នុងការរៀបចំគម្រោងការណ៍, បណ្តុះបណ្តាល, ប្រព្រឹត្តតាម និង ស្ទង់មើលឡើងវិញអំពីកម្មវិធី Title I និង ជំនួយថវិការច្រើនចំណែកផ្សេងៗ ។
2. រាយផ្សាយពត៌មានផ្សេងៗ ដែលទាក់ទងជាមួយគោលដៅនៃកម្មវិធី ។
3. ធ្វើជាអ្នកសម្របសម្រួលរវាងក្រសួងអប់រំ ឌីស្ទ្រីគ និង ក្រុមប្រឹក្សាផ្តល់ឱវាទមាតាបិតាប្រចាំសាលារៀន ដើម្បីបង្កើនភាពសក្តិសិទ្ធិផ្នែករួមចំណែកនៃមាតាបិតានៅតាមសាលារៀន ។
4. ផ្តល់កម្មវិធីហ្វឹកហ្វឺនផ្នែកដឹកនាំសំរាប់មាតាបិតា ។
5. បង្កើនការរួមចំណែកនៃមាតាបិតាឲ្យមានភាពកាន់តែរឹងមាំ ។

ផ្នែកមួយចំណែកនេះនៅក្នុងលក្ខន្តិកៈ គឺគ្មានសិទ្ធិអ្វីសំរាប់បកស្រាយទៅកាន់ក្រុមប្រឹក្សា ឌីខាក់ អំពីការបដិសេធលើកម្មវិធី Title I និង ជំនួយថវិការច្រើនចំណែកផ្សេងៗ ។ ក្រុមប្រឹក្សាត្រូវមានមុខងារជាភ្នាក់ងារផ្តល់ឱវាទ, សម្របសម្រួល និង ស្ទង់មើលឡើងវិញ ដើម្បីពង្រីកគោលដៅនៃកម្មវិធីសិក្សា និង គោលដៅច្បាស់លាស់នៃលក្ខន្តិកៈទាំងអស់នេះ ។ ក្រុមប្រឹក្សា ឌីខាក់ គ្មានអំណាចអ្វីសំរាប់សរសេរចុះ “កុងត្រា” ឬ ចំណាយថវិការរដ្ឋបានឡើយ ។ គ្មានសមាជិកណាម្នាក់នឹងត្រូវទទួលការចែងតម្រូវឲ្យលើកបង្ហាញអំពីចំនួនលុយ, ទ្រព្យសម្បត្តិ ឬ មុខងារផ្សេងៗ ក្រៅតែពីមុខងារដូចបានរៀបរាប់នៅក្នុងនេះសំរាប់តែជួយក្រុមប្រឹក្សា ឌីខាក់ ប៉ុណ្ណោះ ។ ក្រុមប្រឹក្សា ឌីខាក់ គ្មានអំណាចអ្វីសំរាប់បង្ខំឲ្យសមាជិកណាម្នាក់ ឬ ក្រសួងអប់រំ ឌីស្ទ្រីគ ចេញសងថ្លៃបំណុល ឬ ការជាប់ជំពាក់ផ្សេងៗបានឡើយ ។ ក្រុមប្រឹក្សា ឌីខាក់ គ្មានអំណាចលើសពីអ្វីដូចបានរៀបរាប់យ៉ាងច្បាស់លាស់ពីត្រង់នេះទៅ ។

## មាត្រា IV
## សមាជិកភាព
### ផ្នែក 1. ការបង្កើតក្រុមប្រឹក្សា

ដើម្បីនាំមកប្រយោជន៏កាន់តែច្រើនសំរាប់គោលដៅនៃក្រុមប្រឹក្សា គឺសមាជិកភាពត្រូវមានអ្នកតំណាងច្រើនចំណែកជាមនុស្សបង្ហាញការចាប់ចិត្តមកលើកម្មវិធីសិក្សា, ជាពិសេស គឺការរួមចំណែកមកពីមាតាបិតា ដែលមានសិស្សរៀននៅក្នុងសាលាទទួលជំនួយមកពីកម្មវិធី Title I និង ជំនួយថវិការច្រើនចំណែកផ្សេងៗ ។ សមាជិកភាពជាអ្នកតំណាងត្រូវមានដូចតទៅ ...

1. មាតាបិតាត្រូវមានចំនួនជាសមាជិកច្រើននាក់ជាងគេនៅក្នុងក្រុមប្រឹក្សា ឪខាក់ ។ អ្នកតំណាងមាតាបិតាទាំងអស់ត្រូវរស់នៅក្នុងម្តុំតំបន់ក្រសួងអប់រំ ឪស្រ្លីគ ឡុងប៊ីច ព្រមទាំងមានសិស្សរៀននៅក្នុងសាលាទទួលជំនួយមកពីកម្មវិធី Title I និង ជំនួយថវិការច្រើនចំណែកផ្សេងៗ ។
2. សាលារៀនឯកជន ដែលទទួលជំនួយមកពីកម្មវិធី Title I និង ជំនួយថវិការច្រើនចំណែកផ្សេងៗ ត្រូវមានអ្នកតំណាងមាតាបិតានៅក្នុងក្រុមប្រឹក្សា ឪខាក់ ។
3. ចំនួនសមាជិកភាគច្រើន គឺត្រូវជាមាតាបិតានៃសិស្ស ដែលរៀននៅក្នុងសាលាកំពុងទទួលជំនួយថវិការមកពីរដ្ឋ ។
4. បុគ្គលិកសាលារៀនជា school community worker អាចចូលរួមជាសមាជិកនៅក្នុងក្រុមប្រឹក្សា ឪខាក់ បាន ។
5. សមាជិកផ្សេងៗអាចទទួលការជ្រើសរើសបានមកពីក្រុមចំណែកដូចតទៅ ...
    a. ការិយាល័យ Special Projects
    b. ឧបអគ្គនាយកក្រសួងសិក្សាធិការ
    c. នាយកសាលារៀន/អ្នកផ្តល់ឱវាទ
    d. ការិយាល័យ Research & Evaluation
    e. គ្រូបង្រៀន
    f. ក្រសួងនានានៅតាមសហគមន៍
    g. ក្រសួងពាណិជ្ជកម្ម
    h. អ្នកតំណាងផ្សេងៗមកពីសាលារៀនឯកជន ដែលទទួលជំនួយមកពីកម្មវិធី Title I និង ជំនួយថវិការច្រើនចំណែកផ្សេងៗ ក្រោមការផ្គត់ផ្គង់នៃក្រសួងអប់រំ ឪស្រ្លីគ ឡុងប៊ីច
    i. អ្នកតំណាងផ្សេងៗយោងតាមការសម្រេចដោយក្រុមប្រឹក្សា ឪខាក់

## ផ្នែក 2. **ការជ្រើសរើសយកសមាជិក**

ច្បាប់ចែងតម្រូវសំរាប់ការជ្រើសរើសយកសមាជិកនៃក្រុមប្រឹក្សា ឪខាក់ គឺមានដូចតទៅ ...

1. សាលារៀននិមួយៗ ដែលទទួលជំនួយមកពីកម្មវិធី Title I និង ជំនួយថវិការច្រើនចំណែកផ្សេងៗ នឹងជ្រើសរើសយកអ្នកតំណាងមាតាបិតាយ៉ាងហោចណាស់ ពីរ នាក់ ដោយនាយកសាលារៀន ។

2. ការជ្រើសរើសយកសមាជិកផ្សេងៗ គឺនឹងធ្វើការសម្រេចឡើងដោយការិយាល័យ ឬ ក្រសួង ដែលបុគ្គលទាំងអស់នោះកំពុងមានភារកិច្ចជាមួយ ។

3. សមាជិកត្រូវរាយផ្សាយពត៌មានទៅកាន់មាតាបិតាឯទៀតនៅតាមសាលារៀនរបស់ពួកគេរៀងៗខ្លួន ។

## ផ្នែក 3. **រយះពេលសមាជិកភាពសំរាប់អ្នកតំណាងមាតាបិតា**

អ្នកតំណាងមាតាបិតានៃក្រុមប្រឹក្សា ឪខាក់ អាចកាន់មុខងារជាសមាជិកបានក្នុងរយះពេល ពីរ ឆ្នាំ ហើយមានសិទ្ធិទទួលការតែងតាំងឡើងវិញជាបន្តបន្ទាប់ទៅ ។

## ផ្នែក 4. **សិទ្ធិបោះឆ្នោត**

សមាជិកនៃក្រុមប្រឹក្សា ឪខាក់ មានសិទ្ធិបោះឆ្នោតលើបញ្ហានិមួយៗ ដែលបានដាក់បញ្ចូលសំរាប់ការលើកពិគ្រោះដោះស្រាយនៅក្នុងកម្មវិធីប្រជុំ ។

1. ការបោះឆ្នោត ដោយប្រើមនុស្សផ្សេងមកជំនួស ឬ ការបោះឆ្នោត ដោយគូសចម្លើយនៅក្នុងសន្លឹកក្រដាសសំរាប់ផ្ញើតាម គឺមិនអាចធ្វើបាន ។

### ផ្នែក 5. ការផ្តាច់ចោលសមាជិកភាព

ក្រុមប្រឹក្សា ឪខាក់ ដោយទទួលលទ្ធផលបញ្ជាក់ក្នុងការបោះឆ្នោតជាប់សម្លេង ពីរភាគបី ដោយសមាជិកនៃក្រុមប្រឹក្សា គឺអាចបញ្ឈប់មុខងារមួយរយៈខ្លី ឬ ផ្តាច់ចោលមុខងារនៃសមាជិកណាម្នាក់ក៏បាន ។ សមាជិកម្នាក់នោះត្រូវបានទទួលពត៌មានស្តីអំពីការបញ្ឈប់មុខងារមួយរយៈខ្លី ឬ ការផ្តាច់ចោលមុខងារតែម្តងតាមរយៈសរសេរបង្ហាញនៅក្នុងលិខិត បើសិនជាចាំបាច់ ។

### ផ្នែក 6. ការសុំលាលែង

សមាជិកណាម្នាក់ក៏ដោយ គឺអាចសុំលាលែងមុខងារពីក្រុមប្រឹក្សា ឪខាក់ បាន ដោយរាយការណ៍ប្រាប់នាយកគ្រប់គ្រងការិយាល័យ Special Projects ។

### ផ្នែក 7. កន្លែងនៅទំនេរ

កន្លែងនៅទំនេរ គឺអាចដាក់បំពេញបាន ដោយយកមនុស្សមកជំនួស ។ បើរកមនុស្សមកដាក់ជំនួសមិនបាន គឺកន្លែងនឹងត្រូវបំពេញ ដោយប្រើតាមច្បាប់ចែងតម្រូវដូចបានរាយបង្ហាញនៅក្នុង Section 2 ។

## មាត្រា V
## កម្មិកសមាជិក

### ផ្នែក 1. កម្មិកសមាជិក

កម្មិកសមាជិកភាគច្រើននៃក្រុមប្រឹក្សា ឪខាក់ ត្រូវមានជា សហប្រធាន ពីរ នាក់, សហអនុប្រធាន ពីរ នាក់ និង អ្នកសរសេរកំណត់ហេតុ ពីរ នាក់ (ជាបុគ្គលិកប្រចាំឪស្រ្តីត) ។ ក្រុមប្រឹក្សា ឪខាក់ ក៏អាចបោះឆ្នោតជ្រើសរើសយកកម្មិកសមាជិកផ្សេងៗទៀតបានដែរ បើសិនក្រុមប្រឹក្សាមើលទៅឃើញថា ចាំបាច់ ។

### ផ្នែក 2. ការបោះឆ្នោតជ្រើសរើស និង រយះពេលកាន់មុខងារ

សហប្រធាន និង សហអនុប្រធានត្រូវទទួលជាប់ឈ្មោះតាមរយះការបោះឆ្នោត ដោយសមាជិកចូលរួមនៅក្នុងកម្មវិធីប្រជុំ ឪខាក់ ជាលើកដំបូងក្នុងឆ្នាំសិក្សាថ្មី ហើយត្រូវជួយកិច្ចការយ៉ាងសកម្មនៅក្នុងក្រុមប្រឹក្សា ឪខាក់ យ៉ាងតិចបំផុត មួយឆ្នាំ ។ កម្មិកសមាជិកទាំងអស់ត្រូវកាន់មុខងារសំរាប់រយៈពេល ពីរ ឆ្នាំ ។ កម្មិកសមាជិកអាចទទួលជាប់ឈ្មោះសារឡើងវិញបានតាមរយះការបោះឆ្នោតថ្មី ដោយមិនអាចកាន់មុខងារលើសពី ពីរ ឆ្នាំបន្ត ឬ ទំរាំតែកន្លែងអាចរកមនុស្សមកដាក់បំពេញបាន ។ កម្មវិធីប្រជុំសំរាប់គណៈកម្មាធិការ ឪខាក់ គឺបើកសំរាប់តែកម្មិកសមាជិកចូលរួមប៉ុណ្ណោះ ។

មុខងារទទួលខុសត្រូវនៃគណៈកម្មាធិការ ឪខាក់ គឺមានដូចតទៅ ...

1. ត្រូវចូលរួមនៅក្នុងកម្មវិធីប្រជុំគណៈកម្មាធិការ ឪខាក់ ទាំងអស់
2. រៀបចំសាច់រឿងសំរាប់លើកពិគ្រោះនៅក្នុងកម្មវិធីប្រជុំ ឪខាក់
3. ធ្វើការស្ទង់វាស់វែងរាល់ឆ្នាំ និង ពិនិត្យឡើងវិញអំពីលទ្ធផល

### ផ្នែក 3. ការផ្តាច់មុខងារ

កម្មិកសមាជិកណាម្នាក់ក៏ដោយ ដែលជាប់ឈ្មោះតាមការបោះឆ្នោត ឬ ការតែងតាំងឡើងដោយក្រុមប្រឹក្សា ឪខាក់ គឺអាចទទួលការដកហូតមុខងារចេញបាន តាមរយះការបោះឆ្នោតជាប់សម្លេង ពីរភាគបី ដោយសមាជិកចូលរួមនៅក្នុងកម្មវិធីប្រជុំ ឪខាក់ ។

### ផ្នែក 4. កន្លែងនៅទំនេរ

កន្លែងនៅទំនេរសំរាប់មុខងារនៃកម្មិកសមាជិកណាម្នាក់ក៏ដោយ ដោយមូលហេតុមកពីមរណភាព, ការសុំលាលែង, ការដកហូតមុខងារ ឬ ការប្រព្រឹត្តខុសឆ្គងផ្សេងៗ គឺអាចយកកម្មិកសមាជិកផ្សេងមកដាក់ជំនួសបាន ។ បើរកមនុស្សមកដាក់ជំនួសមិនបាន គឺការបោះឆ្នោតគួរចាប់ផ្តើមធ្វើ ដើម្បីជ្រើសរើសយកកម្មិកសមាជិកថ្មីមកដាក់បំពេញ ។

ផ្នែក 5. **មុខងារ**

**ខុសត្រូវ និង មុខងារទូទៅនៃកម្មិកសមាជិក**

1. **សហប្រធាន** – សហប្រធានត្រូវចាត់ចែងនៅក្នុងកម្មវិធីប្រជុំ ឌីខាក់ ទាំងអស់ និង ត្រូវចុះហត្ថលេខាលើលិខិត, របាយការណ៍ និង ក្រដាសស្នាមផ្សេងៗ ទាក់ទងជាមួយក្រុមប្រឹក្សា រួមទាំងបំពេញកិច្ចការទូទៅចាំបាច់ ។

2. **សហអនុប្រធាន** – មុខងារនៃសហអនុប្រធាន គឺត្រូវធ្វើជាអ្នកតំណាងជំនួសសហប្រធាន នៅពេលសហប្រធានជាប់រវល់ និង មិនបានចូលរួម ។ ម្តងម្កាល ពួកគេទទួលធ្វើកិច្ចការ ដែលសហប្រធាន ឬ ក្រុមប្រឹក្សា ឌីខាក់ ពឹងឲ្យធ្វើ ។ យ៉ាងហោចណាស់ គឺសហអនុប្រធានម្នាក់ត្រូវជា មាតា/បិតា នៃសិស្សរៀននៅក្នុងសាលាទទួលជំនួយមកពីកម្មវិធី Title I និង ជំនួយថវិការច្រើនចំណែកផ្សេងៗ ។

3. **អ្នកសរសេរកំណត់ហេតុ** – អ្នកសរសេរកំណត់ហេតុត្រូវសរសេរកំណត់ហេតុយ៉ាងត្រឹមត្រូវនៅក្នុងកម្មវិធីប្រជុំ ឌីខាក់ ទាំងអស់ ... ទាំងកម្មវិធីប្រជុំធម្មតា ទាំងកម្មវិធីប្រជុំពិសេស ហើយត្រូវធ្វើកំណត់ហេតុទាំងអស់ទៅកាន់ការិយាល័យ Special Projects Services ។ បន្ទាប់ទៅ, ការិយាល័យ Special Projects Services នឹងទទួលមុខងារផ្នែកបកប្រែភាសា និង ចែកជូនកំណត់ហេតុទៅកាន់សមាជិកចូលរួមនៅក្នុងកម្មវិធីប្រជុំ ឌីខាក់ លើកក្រោយទៀត, នាយកសាលារៀន និង បុគ្គលិកផ្សេងៗនៅក្នុងក្រសួងអប់រំ ឌីស្រ្ទីគ ដែលមានការចាប់អារម្មណ៍មកលើ ។ បើសិនជាជាប់រវល់មិនបានចូលរួម គឺអ្នកសរសេរកំណត់ហេតុត្រូវរកមនុស្សមកជំនួស ដើម្បីសរសេរកត់ទុកអំពីកំណត់ហេតុទាំងប៉ុន្មាននៅក្នុងកម្មវិធីប្រជុំ ។

**មាត្រា VI**

**គណៈកម្មាធិការ ឌីខាក់ និង ក្រុមប្រឹក្សារង**

ផ្នែក 1. **គោលដៅ**

ដើម្បីបញ្ជាក់ថា កម្មវិធីប្រជុំ ឌីខាក់ ប្រចាំខែពិតជាមានប្រយោជន៍មែនសំរាប់មាតាបិតាចូលរួម គឺក្រុមប្រឹក្សារងសំរាប់ជួយក្រុមប្រឹក្សា ឌីខាក់ ត្រូវបង្កើតឡើងសំរាប់ជួបពិគ្រោះជាមួយនាយកគ្រប់គ្រងការិយាល័យ Special Projects Services ដើម្បីរៀបចំគម្រោងការណ៍, ធ្វើការស្ទង់មើល និង ជួយចាត់ចែងកិច្ចការទូទៅនៅក្នុងកម្មវិធីប្រជុំ ឌីខាក់ ប្រចាំខែ ។

ផ្នែក 2. **ការបង្កើតគណៈកម្មាធិការ**

សមាជិកភាពជាអ្នកតំណាងនៅក្នុងគណៈកម្មាធិការ ឌីខាក់ ត្រូវមាន ...

1. កម្មិកសមាជិកនៃក្រុមប្រឹក្សា ឌីខាក់
2. នាយកគ្រប់គ្រងការិយាល័យ Special Projects Services
3. បុគ្គលិកប្រចាំការិយាល័យ Special Projects Services
4. មាតាបិតាត្រូវមានចំនួនច្រើននាក់ជាងគេក្នុងសមាជិកភាព

ផ្នែក 3. **ការជ្រើសរើសយកក្រុមប្រឹក្សារង**

ក្រុមប្រឹក្សារងត្រូវទទួលការតែងតាំងដោយគណៈកម្មាធិការ ឌីខាក់ បើសិនជាចាំបាច់ ដើម្បីបំពេញកិច្ចការ ។

## ផ្នែក 4. វិន័យប្រើប្រាស់តាម

គណៈកម្មាធិការ ឌីខាក់ អាចបង្កើតវិន័យប្រើប្រាស់សំរាប់ខ្លួនឯងបាន ដែលមានភាពស្រដៀងគ្នាជាមួយលក្ខន្តិកៈដូចបានរៀបរាប់មក ។

## ផ្នែក 5. ចំនួនសមាជិកចាំបាច់

ចំនួនសមាជិកចូលរួមត្រូវមានយ៉ាងតិចបំផុត 51% មុននឹងកម្មវិធីប្រជុំអាចប្រព្រឹត្តទៅបាន លុះត្រាតែគណៈកម្មាធិការ ឌីខាក់ សម្រេចធ្វើអ្វីផ្សេងវិញ ។

## ផ្នែក 6. កម្មវិធីប្រជុំ

គណៈកម្មាធិការ ឌីខាក់ អាចជួបជុំគ្នាទៅពេលណាក៏បានក្នុងឆ្នាំសិក្សា ឲ្យតែមើលទៅឃើញថា ចាំបាច់ ។

បានកែប្រែឡើងវិញនៅៈ ខែសីហា ឆ្នាំ2010

បានទទួលការកែប្រែនៅៈ ខែតុលា ឆ្នាំ2009

Carol Pratt, Long Beach Unified School District Administrative Assistant
Marilyn King, Long Beach Unified School District, Secretary to Administrative Assistant & DCAC Recorder
DCAC Board members: Sandra Scott, Co-Chair Kaco Embery, Co-Chair Rene Woodson, Vice-Chair

បានទទួលការកែប្រែនៅៈ ខែកញ្ញា ឆ្នាំ2005

Ninette Richardson, Long Beach Unified School District Parent Education Coordinator
Alice Sexton, Long Beach Unified School District Teacher on Special Assignment
Nancy Dowell, Long Beach Unified School District Counselor
Sam Keo, Long Beach Unified School District Instructional Assistant – Khmer
Marilyn King, Long Beach Unified School District Secretary
Ana Moran, Long Beach Unified School District Community Liaison
Lydia Marshall, Long Beach Unified School District DCAC Chairperson and parent
Toi Hines, Long Beach Unified School District parent
Sandra Scott, Long Beach Unified School District parent

បានទទួលការកែប្រែ និង ការទទួលស្គាល់ដោយក្រុមប្រឹក្សា ឌីខាក់ នៅៈ ខែកញ្ញា ឆ្នាំ1972, ខែកុម្ភៈ ឆ្នាំ1973, ខែមករា ឆ្នាំ1976, ខែឧសភា ឆ្នាំ1980, ខែកុម្ភៈ ឆ្នាំ1985, ខែមករា ឆ្នាំ1987, ខែកញ្ញា ឆ្នាំ1987, ខែឧសភា ឆ្នាំ1990, ខែមេសា ឆ្នាំ1997, ខែកុម្ភៈ ឆ្នាំ2000, ខែកញ្ញា ឆ្នាំ2001, ខែតុលា ឆ្នាំ2003